toyoko-inn.com
東横INN

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀងក្នុងការកំណត់ផ្ដល់ និងរបៀបបើកប្រាក់ឧបត្ថម្ភ របស់ក្រុមហ៊ុន តូយ៉ូកូ អ៊ីន (ខេមបូឌា) ខូអិលធីឌី

កិច្ចព្រមព្រាងនេះធ្វើឡើងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១រសៀល នៅ ក្រុមហ៊ុន តូយ៉ូកូ អ៊ីន (ខេមបូឌា) **ខូអិលធីឌី** ដោយមានការប្រជុំរវាងនយោជិត ដំណាងនយោជិត (ប្រតិភូបុគ្គលិក) និងនាយកក្រុមហ៊ុនស្ដីពីការព្យួរកិច្ចសន្យាការងាររបស់បុគ្គលិក និងការផ្ដល់ប្រាក់ឧបត្ថម្ភ។ ដោយសារមូលហេតុនៃការរីករាលដាលជំងឺកូវីដ១៩ ដែលបណ្ដាលអោយបាត់បង់ភ្ញៀវ ក៏ដូចជាបាត់បង់ប្រាក់ចំណូលរបស់ក្រុមហ៊ុនផងដែរនោះ ទើបក្រុមហ៊ុនបានសម្រេចព្យួរកិច្ចសន្យាការងារបុគ្គលិកមួយចំនួន២៤នាក់ (ស្រី ២២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥៨នាក់ (ស្រី ៤៥នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០។ និងបានស្ម័គ្រចិត្តផ្ដល់ប្រាក់ឧបត្ថម្ភទៅដល់បុគ្គលិកដែលត្រូវបានព្យួរកិច្ចសន្យាការងារទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ។

ក្រុមហ៊ុននឹងផ្ទេរប្រាក់ឧបត្ថម្ភខាងលើនេះ តាមរយៈលេខគណនេយ្យធនាគាររបស់បុគ្គលិកដែលមានរួច និងតាមរយៈធនាគារឯកទេសវីងសម្រាប់បុគ្គលិកដែលមិនទាន់មាន។

កិច្ចព្រមព្រាងនេះធ្វើឡើងស្របតាមសេចក្ដីណែនាំលេខ.០៥៥/២០ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយមានការឯកភាពពីគ្រប់បុគ្គលិកដែលត្រូវបានព្យួរកិច្ចសន្យាការងារ និងប្រតិភូបុគ្គលិកដែលដំណាងអោយនយោជិតទាំងអស់ដោយស្ម័គ្រចិត្ត និងពុំមានការបង្ខិតបង្ខំអ្វីទាំងអស់។

កិច្ចព្រមព្រាងនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។
ថ្ងៃ សុក្រ ៥ រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០

| ប្រតិភូបុគ្គលិកទី១ | ប្រតិភូបុគ្គលិកទី២ | អ្នកគ្រប់គ្រងសណ្ឋាគារ |
| --- | --- | --- |
| កញ្ញា ឈុំ ស៊ីថា | លោក ភា សុផាត់យុទ្ធ | លោកស្រី **KUMIKO MINAKAWA** |